**ឯកសារជំនួយស្មារតី**
**របស់លោក ស៊ីវ យុត ចៅសង្កាត់ក្រាំងអំពិលក្រុងកំពត ខេត្តកំពត**
**ក្នុងឱកាសចូលរួមជាវាគ្មិនកិត្តិយសក្នុងសន្និសីទសារព័ត៌មាន**
**ស្តីពី"វឌ្ឍនភាពមូលដ្ឋានឃុំ/សង្កាត់ និងទិសដៅការងារបន្ត"**

ទីស្តីការគណៈរដ្ឋមន្ត្រី ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២១

-សូមគោរព **ឯកឧត្តម ផៃ ស៊ីផាន** រដ្ឋមន្ត្រី ប្រតិភូមអមនាយករដ្ឋមន្ត្រី និងជាប្រធានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល នៃទីស្តីការគណៈរដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់ !

-ឯកឧត្តម លោកជំទាវ អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល ជាទីគោរព!

-លោក លោកស្រី ប្រធានក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ ជាទីគោរពរាប់អាន !

ថ្ងៃនេះក្នុងនាមក្រុមប្រឹក្សាសង្កាត់ក្រាំងអំពិល ក្រុងកំពត ខេត្តកំពតនិងក្នុងនាមខ្ញុំបាទផ្ទាល់មានក្តីសោមនស្សរីករាយក្រៃលែងដែលបានចូលរួមសន្និសិទ្ធសារពត៌មានស្តីពី "វឌ្ឍនភាពមូលដ្ឋានឃុំ/សង្កាត់ និងទិសដៅការងារបន្ត" ដែលរៀបចំដោយអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាលនាឱកាសនេះ ជាបន្តទៅនេះខ្ញុំបាទសូមការអនុញ្ញាតិ រាយការសង្ខេបពីស្ថានភាពការអភិវឌ្ឍន៍មូលដ្ឋានសង្កាត់ក្រាំងអំពិលយើងខ្ញុំដូចតទៅៈ

## I-ស្ថានភាពទូទៅនៃរដ្ឋបាលសង្កាត់ក្រាំងអំពិល

**សង្កាត់ក្រាំងអំពិល** ជាសង្កាត់មួយក្នុងចំណោមសង្កាត់ទាំង០៥នៃក្រុងកំពត ខេត្តកំពត ដែលមានទីតាំងជាប់ពីខាងកើតផ្លូវជាតិលេខ៣ ក្នុងក្រុងកំពត ។ សង្កាត់ក្រាំងអំពិលមានផ្ទៃដីសរុប ២.១៧គ.ម ការេ និងមានភូមិចំនួន០២គឺភូមិក្រាំង និងភូមិស្វាយធំ សង្កាត់ក្រាំអំពិលមានប្រជាពលរដ្ឋសរុបចំនួន១,១០៣គ្រួសារ ប្រជាពលរដ្ឋសរុប៤,៧៨៩នាក់ ក្នុងនោះស្រី២,៥៥១នាក់ អាយុ១៨ឆ្នាំឡើងមានចំនួន៤,២១៧នាក់ ស្រី២,២០៥នាក់ និងអ្នកដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតឆ្នាំ២០២០ មានចំនួន៣,០១៥នាក់ ស្រី១,៦៥៧នាក់។ សង្កាត់ក្រាំងអំពិលមានព្រំប្រទល់ៈ

-ខាងជើងទល់នឹងឃុំត្រពាំងធំ ស្រុកទឹកឈូ ខេត្តកំពត

-ខាងត្បូងទល់នឹងសង្កាត់កំពង់កណ្តាល ក្រុងកំពត ខេត្តកំពត

-ខាងលិចទល់នឹង សង្កាត់កំពង់បាយ ក្រុងកំពត ខេត្តកំពត

-ខាងកើតទល់នឹងឃុំត្រពាំងធំ ស្រុកទឹកឈូ ខេត្តកំពត

ជាសង្កាត់មួយស្ថិតក្នុង ចំណុចកណ្តាលទីក្រុងកំពត ជាកត្តាអំណោយផល និងមានសក្តានុពល ទាំងសេដ្ឋកិច្ចនិងសង្គមកិច្ច ជាពិសេសលើវិស័យទេសចរណ៍ ទូរគមនាគមន៍ មានហេដ្ឋារចនាសម្ពន្ធ័ផ្លូវ ផ្លូវកៅស៊ូ ផ្លូវបេតុង គ្រួសក្រហម ប្រពន្ធ័លូ វីហ្គា ទីផ្សារ សាលារៀន វត្តអារាម ព្រះវិហារគ្រីស្តសាសនា មន្ទីរពេទ្យ មណ្ឌលសុខភាព តំបន់ទេសចរណ៍ រមណីដ្ឋាន ផ្ទះបូរាណ សំណង់បេតិភ័ណ្ឌ ប្រពន្ធ័ទឹកស្អាត និងមានសមិទ្ធិផលចជាច្រើនដែលរដ្ឋបាលខេត្តបានអនុវត្តរួមជាមួយមន្ទីរជំនាញ និងរដ្ឋបាលក្រុង។

## II-**វឌ្ឍនៈភាពនិងសមិទ្ធិផលដែលសម្រេចបានកន្លងមក**

### **១-ផ្នែកសេដ្ឋកិច្ច**

### **១.១-ផ្នែកហេដ្ឋារចនាសម្ពន្ធ័**

ក្រោយពេលដែលបានបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាសង្កាត់ក្រាំងអំពិលក្នុងអាណត្តិទី១ (២០០២-២០០៧) និងអាណត្តិទី៤(២០១២-២០១៧) រហូតមកដល់សព្វថ្ងៃនេះឆ្នាំ២០២០ ជាឆ្នាំទី០៤នៃអាណត្តិទី០៤ របស់ក្រុមប្រឹក្សាសង្កាត់ក្រាំងអំពិល ដែលបានអនុវត្តការងារបំរើមូលដ្ឋាន និងបានអនុវត្តមុខងារជាភ្នាក់ងារប្រកបដោយប្រសិទ្ធភាព នៃការរួមចំណែកការអភិវឌ្ឍន៍ក្នុងមូលដ្ឋានប្រកបដោយចីរភាព និងប្រសិទ្ធភាព ដោយកាលពីមុនសង្កាត់ក្រាំងអំពិល ជាឃុំមួយជាប់នឹងផ្លូវជាតិលេខ៣ មានលក្ខណៈជាទីប្រជុំជននៅប៉ែកខាងលើ ក្រៅពីនោះសុទ្ធតែជាវាលស្រែនិងដើមត្នោត មានផ្លូវរទេះគោ២ខ្សែដែលប្រជាកសិករធ្វើដំណើរមកទីផ្សារប៉ុណ្ណោះ ឆ្លងកាត់ក្រុមប្រឹក្សា៤អាណត្តិកន្លងមក ធ្វើអោយសង្កាត់ក្រាំងអំពិលទាំងមូលមាន ហេដ្ឋារចនាសម្ពន្ធ័ មានផ្លូវបេតុង កៅស៊ូ គ្រួសក្រហម ដោយបានប្រើប្រាស់ថវិការាជរដ្ឋាភិបាល និងការគៀងគរពី សប្បុរជនបានកសាងផ្លូវចំនួន២០ខ្សែ ប្រវែងសរុប ២,៤០៣៦ម(ប្រភេទផ្លូវបេទីមីណឺមានប្រវែង៤៩៥ម, ប្រភេទផ្លូវចាក់បេតុងមានប្រវែង៣,២០០ម, ប្រភេទផ្លូវក្រាលគ្រួសក្រហមមានប្រវែង៨,៥០០ម,ប្រភេទផ្លូវដីសប្រវែង ៦,៣០០ម និងប្រភេទផ្លូវលំធម្មតា៥,៥៤១ម) ដែលមានទំហំទទឹង២០ម ,១៨ម,១៦ម,១៤ម,១២ម, អមដោយប្រពន្ធ័លូ និងមួយចំនួនមិនទាន់មានប្រពន្ធ័លូ។ ដោយមានការយកចិត្តទុកដាក់ក្នុងការដឹកនាំគ្រប់គ្រងរដ្ឋបាលសង្កាត់និងមានការចូលរួមពីសប្បុរជន បានចូលរួមជាថវិកាសាងសង់ផ្លូវបេតុង ផ្លូវគ្រួសក្រហម ជាពិសេសប្រជាពលរដ្ឋបានបរិច្ចាកដីផ្ទាល់ខ្លួន ដើម្បីចូលរួមអភិវឌ្ឍន៍មូលដ្ឋាន បានធ្វើអោយសង្កាត់ក្រាំអំពិល ក្លាយជាសង្កាត់មួយដែលមានផ្លូវខ្វាត់ខ្វែង មានប្រពន្ធ័អគ្គិសនី មានបណ្តាញទឹកស្អាតប្រើប្រាស់គ្រប់ខ្នងផ្ទះ ទូទាំងសង្កាត់ និងមានប្រឡាយ២ខ្សែដើម្បីរំដោះទឹកជំនន់នៅរដូវវស្សា ក្រោមការដឹកនាំពីឯកឧត្តម **ជាវ តាយ** អភិបាលនៃគណៈអភិបាលខេត្តកំពត ដើម្បីឆ្លើយតបទៅនឹងតម្រូវការពិតប្រាកដជូនដល់បងប្អូនប្រជាពលរដ្ឋក្នុងមូលដ្ឋានសង្កាត់ក្រាំងអំពិល។

### ១.២-ផ្នែកកសិកម្ម

សង្កាត់ក្រាំងអំពិលមានវិស័យកសិកម្មមានផ្ទៃដីបង្កបង្កើនផលសរុប៦៥ហ.ត ចំណែកការចិញ្ចឹមសត្វវិញមាន៖

-ចិញ្ចឹមគោមានចំនួន៦២ក្បាល ស្មើនឹង២.១១%នៃគ្រួសារក្នុងសង្កាត់

-ចិញ្ចឹមជ្រូកមានចំនួន៣២ក្បាលស្មើនឹង០.៨៦%នៃគ្រួសារក្នុងសង្កាត់

-ចិញ្ចឹមមាន់មានចំនួន១៤៥ក្បាលស្មើនឹង១៦.១៥%នៃគ្រួសារក្នុងសង្កាត់

-ចិញ្ចឹមទាមានចំនួន១២១ក្បាលស្មើនឹង១.២៥%នៃគ្រួសារក្នុងសង្កាត់

និងប្រជាពលរដ្ឋមួយចំនួនមានមុខរបរជាច្រើនទៀត ដូចជាមន្ត្រីរាជការ បុគ្គលិកវិស័យឯកជន អង្គការសមាគមន៍ អាជីវករលក់ដូរ និងកម្មករ ដែលជាកត្តាជំរុញជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកាន់តែប្រឡើងពីមួយថ្ងៃទៅមួយថ្ងៃ។

សក្តានុពលទាំងនេះបានបង្កលក្ខណៈដល់សង្កាត់សម្រាប់រៀបចំនូវផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំខាងមុខនេះនិងដោះស្រាយបាននូវបញ្ហាប្រឈមនានា ឆ្លើយតបទៅនឹងតម្រូវការ ពិតប្រាកដជូនដល់បងប្អូនប្រជាពលរដ្ឋរស់នៅក្នុងមូលដ្ឋាន។

### ១.៣-ផ្នែកសេវាកម្មនិងទេសចរណ៍

ដោយសារមានការអភិវឌ្ឍន៍គ្រប់ផ្នែកជាពិសេសវិស័យទេសចរណ៍និងវិស័យធនាគារនៅក្នុងសង្កាត់ក្រាំអំពិលមានដូចជា៖

១-ធនាគារចំនួន ២កន្លែង

២-មីក្រូហិរញ្ញវត្ថុចំនួន ៧កន្លែង

៣-សណ្ឋាគារនិងផ្ទះសំណាក់ចំនួន ១៧កន្លែង

៤-មន្ទីរពេទ្យឯកជនចំនួន ២កន្លែង

៥-តំបន់ប្រវត្តិសាស្ត្រ ស្ថានីយ៍រថភ្លើង ០១កន្លែង

៦-ការផលិតនំដែលជាការងារភូមិ១ផលិតផល១ មានចំនួន ៣កន្លែង

៧-សិប្បកម្មជាងឈើ ០១កន្លែង

៨-ស្ថានីយ៍ប្រេងឥន្ធនះ ចំនួន៤កន្លែង

៩-សិប្បកម្មផលិតទឹកកក ចំនួន៣កន្លែង

១០-ចំណតរថយន្ត ០១កន្លែង

១១-ចំណតរ៉ឺម៉ក ០១កន្លែង

## ២-ផ្នែកសង្គមកិច្ច

ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា សម្ដេចតែងតែយកចិត្តទុកដាក់គិតគូដល់គោនលនយោយបានគាំពាសង្គមដោយបានឧបត្ថម្ភសាច់ប្រាក់ដល់ជនក្រីក្រ កុមារក្រោមអាយុ២ឆ្នាំ និងស្ត្រីមានផ្ទៃពោះ។ ដោយសារស្ថានភាពក្នុងប្រទេសកម្ពុជាបានជួបបញ្ហាជំងឺកូវីដ១៩ ធ្វើអោយជីវភាពបងប្អូនប្រជាពលរដ្ឋជួបការលំបាកក្នុងការប្រកបរបបរកស៊ី បាត់បង់ប្រាក់ចំណូលជាច្រើន ទើបរាជរដ្ឋាភិបាលបានគិតគូផ្ដល់ប្រាក់ឧបត្ថម្ភ ជូនដល់គ្រួសារក្រីក្រទូទាំងប្រទេស ក្នុងនោះសង្កាត់ក្រាំងអំពិលមានគ្រួសារក្រីក្រសរុប ២៤៣គ្រួសារ ដែលទទួលបានការឧបត្ថម្ភសាច់ប្រាក់ពីរាជរដ្ឋាភិបាល តាំងពីឧសភា ឆ្នាំ២០២០មកម្លេះ ហើយនិងបានចុះឈ្មោះជូនគ្រួសារក្រីក្រដែលពិនិត្យផ្ទៃពោះ សំរាលបានចំនួន២១នាក់ និងចុះឈ្មោះកុមារក្រោមអាយុ២ឆ្នាំ បានចំនួន ៤នាក់ ។

*បានបង្កើតសមាគមនមនុស្សចាស់:បង្កើតឡើងក្នុងគោលបំណងដើម្បីជួយគ្នាក្នុងពេលមានការឈឺស្កាត់និងមរណៈភាព (ប្រមូលលុយប្រចាំខែសម្រាប់សមាជិក ហើយក្នុងករណីសមាជិកណាម្នាក់ឈឺមរណៈភាពនឹងដកលុយដែលបានប្រមូលនោះក្នុងចំណែកណាមួយដើម្បីជួយសំរាលបន្ទុក)។

## ២.១ វិស័យអប់រំនិងស្ថានភាពសង្គមកិច្ច

វិស័យអប់រំក្នុងសង្កាត់ក្រាំងអំពិលមានសាលាបឋមសិក្សារដ្ឋ២កន្លែងមាន១៤បន្ទប់ស្មើ១២ថ្នាក់ មានសិស្សសរុប២០៦នាក់ មានគ្រូសរុប១២នាក់ មានអនុវិទ្យាល័យរដ្ឋ១កន្លែងមាន១២បន្ទប់ស្មើ នឹង៣ថ្នាក់មានសិស្សានុសិស្សសរុប៥៨នាក់ មានគ្រូ១២នាក់ និងអនុវិទ្យាល័យឯកជន១កន្លែងមាន៣បន្ទប់ស្មើនឹង៣ថ្នាក់មានសិស្សសរុប៥៦នាក់ គ្រូ៨នាក់។មត្តេយ្យសកគមន៍មាន១កន្លែង ស្មើនឹង១ថ្នាក់ មានសិស្សសរុប២២នាក់ គ្រូបង្រៀន១នាក់ វិស័យសុខាភិបាលមានមណ្ឌលភាព១កន្លែង មានបុគ្គលិក១២នាក់ បំរើសេវាសុខភាពជូនប្រជាពលរដ្ឋ២៤ម៉ោងលើ២៤ម៉ោង និងមានភ្នាក់ងារសុខភាពភូមិចំនួន៥នាក់។ នៅក្នុងសង្កាត់ក្រាំងអំពិលគ្រួសារមានបង្គន់អនាម័យប្រើប្រាស់ចំនួន១,១០៣គ្រួសារ។

ចំពោះជនងាយរងគ្រោះនិងជនពិការសរុបមាន៦២នាក់ និងអាហាររូបត្ថម្ភ ផ្នែកវិស័យសុខភាពសង្គម ។

-សង្កាត់ក្រាំងអំពិលមានពហុកីឡដ្ឋានចំនួន០១កន្លែង សម្រាប់ឲ្យបងប្អូនប្រជាពលរដ្ឋលេងកីឡា ហាត់ប្រាណ និងសម្រាប់រៀបចំពិធីបុណ្យជាតិ និងកម្មវិធីផ្សេងៗ ។

### ៣-ផ្នែកគ្រប់គ្រងធនធានធម្មជាតិបរិស្ថាន

ប្រជាពលរដ្ឋក្នុងសង្កាត់ក្រាំងអំពិលមានជីវភាពកាន់តែប្រសើរឡើងស្របតាមអភិបាលកិច្ចល្អរស់នៅប្រកបដោយសុខមាលភាពក្នុងបរិស្ថានល្អនិងមានសុខសុវត្ថិភាព។សង្កាត់ក្រាំងអំពិលការអភិរក្សតំបន់ ព្រែកចាក និង អង្គបុរាណ មានមណ្ឌលកែច្នៃជីសរីរាង្គ១កន្លែង និងមានអាងស្តុបទឹកកង្វក់១កន្លែងមានទំហំ៣ ហ.ត សម្រាប់ធ្វើជាស្ថានីយ៍បូមទឹកច្រោះទឹកកង្វក់។

សង្កាត់ក្រាំងអំពិលបានចូលរួមប្រកួតប្រជែងកម្មវិធីទីក្រុងស្អាតរំដួលបីទង(បានជាប់ជ័យលាភីរំដួលបីទង ០២អាណ្ណតិ)

### ៤-ផ្នែករដ្ឋបាលនិងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

### ៤.១-ផ្នែករដ្ឋបាល

រដ្ឋបាលមានសាលាសង្កាត់ថ្មីតាមស្តង់ដារបស់ក្រសួងមហាផ្ទៃ សម្រាប់បំរើនិងផ្តល់សេវាជូនប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន និង មានការផ្សព្វផ្សាយនៅវេទិកាសាធារណៈ ជូនដល់បងប្អូនប្រជាពលរដ្ឋក្នុងសង្កាត់ក្រាំងអំពិល ឃើញថាបងប្អូនប្រជាពលរដ្ឋមានការយល់ដឹងបានច្រើនអំពីការមកទទួលសេវាហើយសង្កាត់ក៏បានបំរើសេវាសាធារណៈជូនដល់ប្រជាពលរដ្ឋបានទាន់ពេលវេលាផងដែរ ដោយក្នុងឆ្នាំ ២០២០ បងប្អូនប្រជាពលរដ្ឋបានមកទទួលសេវាចុះសំបុត្រកំណើត សំបុត្របញ្ជាក់កំណើត សំបុត្រអាពាហ៍ពិពាហ៍ និងសំបុត្រមរណៈភាពបានដូចខាងក្រោមៈ

១-សំបុត្រកំណើតបាន ៧៨នាក់ ស្រី៤០នាក់

២-សំបុត្របញ្ជាក់កំណើតបាន ៣៣នាក់ ស្រី១៥នាក់

៣-សំបុត្រអាពាហ៍ពិពាហ៍បាន ៦៥គូ

៤-សំបុត្រមរណៈភាព ២៧នាក់ ស្រី១៤នាក់

សង្កាត់ក្រាំងអំពិលក៏ជាសង្កាត់មួយក្នុងចំណោមសង្កាត់ដែលបានចុះបញ្ជីអគ្រានុកូលដ្ឋានតាមប្រពន្ធ័សាកល្បង និងមានច្រកចេញចូលតែមួយសេវាអត្តសញ្ញាណកម្មផងដែរ។សង្កាត់ក្រាំងអំពិល ជាជាសមាជិកក្នុងសមាគមក្រុមប្រឹក្សា ក្រុង ស្រុក ឃុំ សង្កាត់ ក្នុងខេត្តកំពត និងជាសមាជិកភាពរបស់សម្ពន្ធ័ភាពជាតិ ក្រុប្រឹក្សាថ្នាក់មូលដ្ឋាននៃព្រះរាជាណាចក្រកម្ពុជា ដើម្បីចែករំលែកបទពិសោធននិងការពង្រឹងស្ថាប័នព្រមទាំង ពង្រឹងសមត្ថភាពក្រុមប្រឹក្សាដែលបានជាប់ឆ្នោតថ្មី នឹងដើម្បីប្រមូលនៅបញ្ហាប្រឈមនៅមូលដ្ឋាន រកដំណោះស្រាយនិងស្វែងរកដៃគូ មានការគាំទ្រទាំងបច្ចេកទេស សំភារៈថវិកា-ល-។

**៤.១-សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ**

សង្កាត់ក្រាំងបានរៀបចំធ្វើវេទិកាសាធារណៈស្តីពីតម្រូវការ និងសំណូមពររបស់ប្រជាពលរដ្ឋជារៀងរាល់ខែ ដើម្បីស្វែងយល់ពីការពីសុខទុក្ខ ពីការចង់បាននិងតម្រូវការនៅមូលដ្ឋាន របស់បងប្អូនប្រជាពលរដ្ឋ និងចុះសួរសុខទុកតាមខ្នងផ្ទះបន្ថែមទៀតនិងចុះផ្សព្វផ្សាយពីកាការពារខ្លួនពីជំងឺកូវីដ១៩ និងបានចែកខិតបណ្ណ័ អាល់កុល ដែលសំលាប់មេរោគ និងបិទខិតបណ្ណ័តាមខ្នងផ្ទះជាច្រើន។ ហើយសង្កាត់ក្រាំងអំពិល រក្សាបានបរិយាកាសសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ មានភាពល្អប្រសើរច្រើន ដោយសារកំលាំងប៉ុស្តិ៍ ចុះរដ្ឋបាលចំហរជារៀងរាល់សប្តាហ៍ និងចុះរដ្ឋបាលចំហរ ជារៀងរាល់ខែនៅតាមផ្ទះសំណាក់ សណ្ឋាគារ បន្ទប់ជួល ហើយកំលាងប៉ុស្តិ៍តែងតែចុះពិនិត្យនៅការស្នាក់នៅបណ្តោះអាសន្ន ក៏ដូចជាស្នាក់នៅអចិន្ត្រៃរបស់ប្រជាពលរដ្ឋដែលមករស់នៅនិងប្រកបរកស៊ីនៅសង្កាត់ក្រាំងអំពិល ហើយអំពើហិង្សា អំពើធក់ប្លន់ ថ្នាំញៀនក៏មិនសូវកើតមានដែរ។ហើយជារៀងរាល់ខែសង្កាត់និងកំលាំងប៉ុស្តិ៍មានកិច្ចប្រជុំផ្សព្វផ្សាយអំពីភូមិ ឃុំ សុវត្ថិភាព ជូនដល់បងប្អូនប្រជាពលរដ្ឋ ជាញឹកញាប់ ទើបធ្វើអោយសង្កាត់ក្រាំងអំពិលនិងប៉ុស្តិ៍រដ្ឋបាល ទទួលបានលិខិតសរសើរពីរាជរដ្ឋាភិបាលកម្ពុជា ដែលមានស្នាដៃល្អក្នុងការអនុវត្តនគោលនយោបាយ "ភូមិ-ឃុំសុវត្ថិភាព" ក្នុងរយៈពេល១០ឆ្នាំកន្លងមកនេះ។

១-ឆ្នាំ២០១១ ជ័យលាភីប្រភេទ២

២-ឆ្នាំ២០១២ ជ័យលាភីប្រភេទ២

៣-ឆ្នាំ២០១៣ ជ័យលាភីប្រភេទ២

៤-ឆ្នាំ២០១៤ ជ័យលាភីប្រភេទ១

៥-ឆ្នាំ២០១៥ ជ័យលាភីប្រភេទ២

៦-ឆ្នាំ២០១៦ ជ័យលាភីប្រភេទ២

៧-ឆ្នាំ២០១៧ ជ័យលាភីប្រភេទ១

៨-ឆ្នាំ២០១៨ ជ័យលាភីប្រភេទ២

៩-ឆ្នាំ២០១៩ ជ័យលាភីប្រភេទ២

១០-ឆ្នាំ២០២០ ជ័យលាភីប្រភេទ២

III-**ទិសដៅបន្តនិងសំណូមពរ**

-ក្នុងឆ្នាំ២០២០នេះ រដ្ឋបាលសង្កាត់បានសម្រេចនៅស្នាដៃមួយចំនួនក៏ពិតម៉ែន តែមិនទាន់បានឆ្លើយតបទាំងស្រុងទៅនឹងការចង់បានរបស់បងប្អូនប្រជាពលរដ្ឋនៅឡើយ តែយ៉ាងណារដ្ឋបាលសង្កាត់

នឹងព្យាយាមឆ្លើមយតបអោយបានល្អនៅឆ្នាំខាងមុខៗទៀត។ ផ្អែកទៅលើសៀវភៅផែនការ៥ឆ្នាំ និងកម្មវិធីវិនិយោគប្រចាំឆ្នាំ។

-បន្តការយកចិត្តទុកដាក់ បំរើសេវារដ្ឋបាលជូន ប្រជាពលរដ្ឋអោយទាន់ពេលវេលា ។

-ផ្សព្វផ្សាយពីការបំរើសេវាសាធារណៈ និងសេវាសំណូមពរ ជូនដល់ប្រជាពលរដ្ឋអោយបានគ្រប់ៗគ្នា និងអោយមានតម្លាភាព។

-បន្តិការខិតខំពង្រឹងការអនុវត្តគោលនយោបាយ ភូមិ ឃុំ សុវត្ថិភាព អោយកាន់តែល្អបន្ថែមទៀត

-បន្តការឆ្លើយតបការសំណូមពរបងប្អូនប្រជាពលរដ្ឋដែលបានលើកឡើងក្នុងវេទិកាសាធារណៈ

-បន្តការអភិវឌ្ឍន៍ ហេដ្ឋារចនាសម្ពន្ធ័ ផ្លូវ លូ ដែលជាអាទិភាពចាំបាច់របស់រដ្ឋបាលសង្កាត់

-បន្តការផ្សព្វផ្សាយ គៀងគរ រកសប្បុរជន ដើម្បីចូលរួមអភិវឌ្ឍន៍នៅក្នុងមូលដ្ឋាន។

-ជំរុញការធ្វើផែនការកម្មវិធីវិនិយោគអោយបានទាន់ពេលវេលា។

-បន្តការយកចិត្តទុកដាក់ត្រួតពិនិត្យតាមដានការអនុវត្តនូវកម្មវិធិឧបត្ថម្ភសាច់ប្រាក់ជូនប្រជាពលរដ្ឋ និងដោះស្រាយអោយទាន់ពេលវេលានៅពេលដែលបងប្អូនប្រជាពលរដ្ឋដកប្រាក់មិនបាន។

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធពរបវរមហាប្រសើរ ជូនដល់ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអង្គពិធីទាំងមូល សូមជួបប្រទះតែនឹងពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈកុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ**